**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តត្បូងឃ្មុំ**

**លេខ:** ០០៦........

ចូល លេខ: ៤៥ ៦៩
មកដល់ថ្ងៃទី ៧ ខែ ៨ ឆ្នាំ ១៦
ម៉ោង ៩:០០

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ

## អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីសំណើសុំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជំរុញការអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥ - ២០១៨
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តត្បូងឃ្មុំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **លី ឡេង** | អភិបាលរង នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. លោក **សុខ វណ្ណា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក **ពាង ណារិទ្ធ** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៤. លោក **ម្ជួនសេង សុវិឡា** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | សមាជិក |
| ៥. លោក **គីម វិត្យា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៦. លោក **ស៊ាង ដារ៉ា** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧. លោក **ឡុង ឆាម** | អភិបាលស្រុកពញាក្រែក | សមាជិក |
| ៨. លោក **កេង ម៉ិនណា** | អភិបាលស្រុកត្បូងឃ្មុំ | សមាជិក |

| | | |
|---|---|---|
| ៩. លោក **ស្រេង លី** | អភិបាលស្រុកក្រូចឆ្មារ | សមាជិក |
| ១០. លោក **ចេង ម៉ុណ្ណារ៉ា** | អភិបាលស្រុកមេមត់ | សមាជិក |
| ១១. លោក **នាដ្ឋ វ៉ាឌុធ** | អភិបាលស្រុកតំបែរ | សមាជិក |
| ១២. លោក **ខ្ចន ម៉ុណ្ណារ៉ា** | អភិបាលស្រុកអូររាំងឪ | សមាជិក |
| ១៣. លោក **ជា ណារ៉ុន** | អភិបាលក្រុងសួង | សមាជិក |
| ១៤. កញ្ញា **សឿន ឌួចលៀង** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | មន្ត្រីបង្គោល |
| ១៥. លោក **សុខ សុភ័ក្ត្រ** | មន្ត្រី នៃមន្ទីរមុខងារសាធារណៈខេត្ត | មន្ត្រីបង្គោល។ |

**ប្រការ២ ._**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរវាងរដ្ឋបាលខេត្ត ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការងារអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈជូនប្រធានស្ថាប័នសាមីជាប្រចាំ
- វាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោល ក្នុងការស្វែងរកនិងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាពការអនុវត្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការងាររៀបចំរបាយការណ៍និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករ ដែលទាក់ទងទៅនឹងវឌ្ឍភាព នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត មកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញ នៃក្រសួងមុខងារសាធារណៈ។

**ប្រការ៣ ._**

នាយក នាយករងរដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ អង្គភាពជំនាញខេត្ត នាយកទីចាត់ការ ប្រធានអង្គភាព ប្រធានការិយាល័យចំណុះរចនាសម្ព័ន្ធសាលាខេត្ត អភិបាលក្រុង ស្រុក ប្រធានការិយាល័យជំនាញក្រុង ស្រុក និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ត្បូងឃ្មុំ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦

**អភិបាលខេត្ត**

ប្រាជ្ញ ចន្ទ

**កន្លែងទទួល**:

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-ក្រុមប្រឹក្សាខេត្ត

" ដើម្បីជូនជ្រាប"

-ដូចប្រការ៣

-ឯកសារ-កាលប្បវត្តិ